**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល** ថ្ងៃច័ន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

លេខ ៧៣៣ ប.ជ.ស រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបម្រើសេវាបើកផ្តល់ប្រាក់គោលនយោបាយរបបសន្តិសុខសង្គមសម្រាប់ពីរសប្តាហ៍លើកទី២ ដើម្បីបើកផ្តល់ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល

បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល "ប.ជ.ស." មានកិត្តិយស សូមគោរពជម្រាបជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុក នៅតាមបណ្តាខេត្ត រួមមាន ÷

| | | |
|---|---|---|
| ១ - ខេត្តកណ្តាល | ៩ - ខេត្តបន្ទាយមានជ័យ | ១៧ - ខេត្តក្រចេះ |
| ២ - ខេត្តកំពង់ចាម | ១០ - ខេត្តពោធិ៍សាត់ | ១៨ - ខេត្តស្ទឹងត្រែង |
| ៣ - ខេត្តត្បូងឃ្មុំ | ១១ - ខេត្តកំពង់ឆ្នាំង | ១៩ - ខេត្តមណ្ឌលគិរី |
| ៤ - ខេត្តស្វាយរៀង | ១២ - ខេត្តកំពង់ស្ពឺ | ២០ - ខេត្តរតនគិរី |
| ៥ - ខេត្តព្រៃវែង | ១៣ - ខេត្តព្រះសីហនុ | ២១ - ខេត្តឧត្តរមានជ័យ |
| ៦ - ខេត្តកំពង់ធំ | ១៤ - ខេត្តកំពត | ២២ - ខេត្តប៉ៃលិន |
| ៧ - ខេត្តសៀមរាប | ១៥ - ខេត្តកែប | ២៣ - ខេត្តព្រះវិហារ |
| ៨ - ខេត្តបាត់ដំបង | ១៦ - ខេត្តតាកែវ | ២៤ - ខេត្តកោះកុង |

សូមមេត្តាជ្រាបថា ប្រាក់គោលនយោបាយសោធនសម្រាប់ពីរសប្តាហ៍ លើកទី ២ ក្នុងខែសីហា **ឆ្នាំ២០១៩ នឹងត្រូវបានបើកផ្តល់ ចាប់ពីថ្ងៃពុធ ១៣រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹង ថ្ងៃទី២៨ខែសីហា ឆ្នាំ២០១៩ តទៅ** តាមប្រព័ន្ធធនាគារ អេស៊ីលីដា ភីអិលស៊ី នៅគ្រប់សាខានៅ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវយកភ្ជាប់មកជាមួយនូវសៀវភៅគណនីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ចំពោះប្រាក់គោលនយោបាយរបបសន្តិសុខសង្គមរបស់សពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងប្រាក់គោលនយោបាយប្រចាំខែសម្រាប់អ្នកនៅក្នុងបន្ទុករបស់សពនិវត្តជន អ្នកនៅក្នុងបន្ទុករបស់សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងកូនកំព្រារបស់សពមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំបើកជូនដល់គេហដ្ឋាន ឬតាមសាលាឃុំ សង្កាត់នៅតាមបណ្តាខេត្តនីមួយៗ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុកនៅតាមបណ្តាខេត្ត មេត្តាជ្រាបជាព័ត៌មាន ។ ក្នុងករណីនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មានជំងឺមិនអាចទៅបើកប្រាក់សោធននៅធនាគារបាន ឬទទួលមរណភាព សូមអ្នកនៅក្នុងបន្ទុក និងអ្នកដែលបានទទួលសិទ្ធិបើកប្រាក់សោធនប្រចាំខែ មេត្តាជូនដំណឹងជាបន្ទាន់មកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធទូរស័ព្ទលេខ **023 726 491 - 023 987 512 - 023 987 523** ឬតាមរយៈ **E-mail: info@nssfc.gov.kh** ដោយសេចក្តីអនុគ្រោះ ។

**បញ្ជាក់** : ប.ជ.ស. មានគេហទំព័រ www.nssfc.gov.kh
Facebook page: បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល - បជស
(https://www.facebook.com/nssfc4)

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមប្រឹក្សាភិបាល នៃ ប.ជ.ស.
- គ្រប់សាលាខេត្ត
  "ដើម្បីជូនជ្រាប"
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

នាយក

ម៉ែន_សុបិត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ថ្ងៃ ចន្ទ ១១រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

លេខ ៧៣១ ប.ជ.ស

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបម្រើសេវាបើកផ្តល់ប្រាក់គោលនយោបាយរបបសន្តិសុខសង្គមសម្រាប់ពីរសប្តាហ៍លើកទី២ ដើម្បីបើកផ្តល់ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល នៅរាជធានីភ្នំពេញ

បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល "ប.ជ.ស." មានកិត្តិយស សូមគោរពជម្រាបជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុកនៅរាជធានីភ្នំពេញ បានជ្រាបថា ប្រាក់គោលនយោបាយសោធនសម្រាប់ពីរសប្តាហ៍ លើកទី២ ក្នុងខែសីហា ឆ្នាំ២០១៩ នឹងត្រូវបានបើកផ្តល់ចាប់ពីថ្ងៃ ចន្ទ ១១រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៩ តទៅ តាមប្រព័ន្ធធនាគារកាណាឌីយ៉ា ក.អ នៅគ្រប់សាខានៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវយកភ្ជាប់មកជាមួយនូវសៀវភៅគណនីរបស់ធនាគារ កាណាឌីយ៉ា ក.អ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ចំពោះប្រាក់គោលនយោបាយរបបសន្តិសុខសង្គមរបស់សពនិវត្តជន របស់សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងប្រាក់គោលនយោបាយប្រចាំខែសម្រាប់អ្នកនៅក្នុងបន្ទុករបស់សពនិវត្តជន អ្នកនៅក្នុងបន្ទុករបស់សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងកូនកំព្រារបស់សពមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំបើកជូនដល់គេហដ្ឋាន ឬតាមសាលាសង្កាត់ សាលាខណ្ឌ នៅរាជធានីភ្នំពេញ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុកទាំងអស់នៅរាជធានីភ្នំពេញ មេត្តាជ្រាបជាព័ត៌មាន ។ ក្នុងករណីនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មានជំងឺមិនអាចទៅបើកប្រាក់សោធននៅធនាគារបាន ឬទទួលមរណភាព សូមអ្នកនៅក្នុងបន្ទុក និងអ្នកដែលបានទទួលសិទ្ធិបើកប្រាក់សោធនប្រចាំខែ មេត្តាជូនដំណឹងជាបន្ទាន់មកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល តាមទូរស័ព្ទលេខ : **023 726 491 - 023 987 512 - 023 987 523** ឬតាមរយៈ **E-mail: info@nssfc.gov.kh** ដោយសេចក្តីអនុគ្រោះ ។

**បញ្ជាក់** : ប.ជ.ស. មានគេហទំព័រ www.nssfc.gov.kh
Facebook page: បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល - បជស
(https://www.facebook.com/nssfc4)

ប្រធាន

ម៉ែន_សុបិត្រ

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមប្រឹក្សាភិបាល នៃ ប.ជ.ស.
- សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ធនាគារ កាណាឌីយ៉ា ក.អ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ